# សង្ខេបសំរាប់គោលនយោបាយ

ធ្នូ 2006, លេខ 05

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ធ្វើការស្រាវជ្រាវ និងវិភាគ ដើម្បីរួមចំណែក
ក្នុងការកសាងយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍មានចិរភាព

# កម្មវិធីប្រមូលផលដើមដៃ: ឱកាសសំរាប់ជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា

ហ៊ីង វុត្ថា

អត្ថបទសង្ខេបសំរាប់គោលនយោបាយនេះ ផ្តល់ទស្សនៈជាទូទៅស្តីពី កម្មវិធីប្រមូលផលដើមដៃ (EHP) ដោយរៀបរាប់បង្ហាញពីឱកាសនាំចេញដែលជាប់ទាក់ទង និងលើកជាអនុសាសន៍ខាងគោលនយោបាយសំរាប់ទាំងរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីអាចទាញយកផលប្រយោជន៍បានកាន់តែច្រើនពីកម្មវិធីនេះ ។

## ១. សេចក្តីផ្តើម

កម្មវិធីប្រមូលផលដើមដៃ មានចែងឡើងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (អាស៊ាន) និងសាធារណៈរដ្ឋចិនប្រជាមានិត[1] ដោយមានគោលដៅពន្លឿនការអនុវត្តន៍សេរីភាវូបនីយកម្មពាណិជ្ជកម្មកសិកម្ម ។ កម្មវិធីទាក់ទិននឹងដំណាំកសិកម្មចំនួន ៨ ក្រុម រួមមានសត្វរស់ សាច់និងគ្រឿងក្នុងអាចបរិភោគបាន ត្រី ផលិតផលពីទឹកដោះ ផលិតផលធ្វើពីសត្វផ្សេងៗទៀត ដើមរុក្ខជាតិរស់ បន្លែ ហើយនិងផ្លែឈើនិងគ្រាប់ឈើបរិភោគបាន ។ កម្មវិធីមានកំណត់ពេលបីឆ្នាំ ដើម្បីធ្វើការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ ដោយត្រូវចាប់ផ្តើមអនុវត្តនៅខែមករា ២០០៤ សំរាប់បណ្តាប្រទេសសមាជិកដើមនៃអាស៊ាន និងប្រទេសចិន និងមានផ្តល់រយៈពេលបន្ថែមមួយចំនួនទៀតសំរាប់ប្រទេសសមាជិកអាស៊ានថ្មីដែលមានកម្ពុជា ឡាវ ភូមា និងវៀតណាម ។ អ្នកកសាងគោលនយោបាយរំពឹងថា កម្មវិធីប្រមូលផលដើមដៃនឹងជួយបង្កើនការនាំចេញផលិតផលកសិកម្មទៅវិញទៅមក ហើយផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចសំរាប់បណ្តាប្រទេសជាសមាជិក ។ នៅខែកក្កដា ឆ្នាំ២០០៤ ពាណិជ្ជកម្មរវាងអាស៊ាន និងចិនលើមុខផលិតផលនៃកម្មវិធីប្រមូលផលដើមដៃ មានតំលៃរហូតដល់ ១,១១ពាន់លានដុល្លារ រឺកើនឡើង ៤២,៣% ធៀបនឹងខែដូចគ្នាឆ្នាំ២០០៣ ក្នុងនេះការនាំចេញរបស់អាស៊ានទៅប្រទេសចិនមានចំនួន ៦៨០លានដុល្លារ រឺកើនឡើង ៤៩,៨% ។

កម្ពុជាជាប្រទេសមានសក្តានុពលច្រើនក្នុងវិស័យកសិកម្ម[2] បើធៀបនឹងប្រទេសអាស៊ានឯទៀត ប៉ុន្តែមាននាំចេញផលិតផលកសិកម្មតិចតួចប៉ុណ្ណោះត្រឹម ២,៥% នៃការនាំចេញសរុបរបស់ប្រទេសអាស៊ាន ។ ការនាំចេញក៏រិតទាបនេះ បណ្តាលមកពីផលិតកម្មកសិកម្មមានកំណើនយឺតៗត្រឹម ៣,៣% នៅកំឡុងពេល ១៩៩៤-២០០៤ ហើយនិងលទ្ធភាពចូលទីផ្សារនៅក្នុងតំបន់ និងនៅអន្តរជាតិ សំរាប់ការនាំចេញផលិតផលកសិកម្មនៅមានក៏រិត ។

យោងតាមលក្ខណៈផ្សេងៗនៃកម្មវិធី និងតំរូវការដ៏ច្រើននៃទីផ្សារចិនចំពោះផលិតផលកសិកម្មមួយចំនួន អត្ថបទសង្ខេបសំរាប់គោលនយោបាយនេះ នឹងវែកញែកបង្ហាញថា កម្មវិធីប្រមូលផលដើមដៃ មានផ្តល់ឱកាសសេដ្ឋកិច្ចយ៉ាងច្រើនដល់ប្រទេសកម្ពុជា ។ ការចូលរួមក្នុងកម្មវិធីប្រមូលផលដើមដៃ គឺជាមធ្យោបាយដ៏សមស្របសំរាប់ប្រទេសពឹងផ្អែកលើកសិកម្មដូចជាកម្ពុជាយើង ដើម្បីជំរុញការនាំចេញផលិតផលកសិកម្ម និងការអភិវឌ្ឍន៍វិស័យកសិកម្មឱ្យក្លាយទៅជាប្រភពមួយទៀតនៃកំណើនសេដ្ឋកិច្ច ។ ប្រទេសកម្ពុជាត្រូវមានយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដើម្បីទទួលបានផលចំណេញកាន់តែច្រើនពីគំរោងកម្មវិធីប្រមូលផលដើមដៃ ។ អត្ថបទនេះ មានគោលដៅផ្តល់ព័ត៌មានដល់កិច្ចពិភាក្សាខាងគោលនយោបាយដោយផ្តោតទៅលើសំណួរសំខាន់ពីរ តើកម្ពុជាមានផលិតផលនាំចេញសក្តានុពលអ្វីខ្លះនៅក្រោមកម្មវិធីប្រមូលផលដើមដៃ និងតើកម្ពុជាគួរធ្វើអ្វីខ្លះ ដើម្បីបង្កើនលទ្ធភាពនាំចេញផលិតផលសក្តានុពលទាំងនេះ?

## ២. លក្ខណៈផ្សេងៗនៃកម្មវិធីប្រមូលផលដើមដៃ

កម្មវិធីប្រមូលផលដើមដៃ គ្របដណ្តប់ផលិតផល ៥៦២មុខ ពីជំពូកទី១-៨ នៅក្នុងប្រព័ន្ធសុខដុមនីយកម្មពន្ធគយ (Harmonized System - HS) ។ ផលិតផលទាំងអស់ដែលស្ថិតនៅក្រោមកម្មវិធីប្រមូលផលដើមដៃ ចែកចេញជា ៣ប្រភេទ សំរាប់ការកាត់បន្ថយនិងលុបបំបាត់ពន្ធគយ យោងតាមក៏រិតនៃពន្ធគយដែលមានលក្ខខណ្ឌអនុគ្រោះ

បំផុតផ្នែកពាណិជ្ជកម្ម (Most Favored Nation - MFN) ដែលប្រែប្រួលខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ក្រុមផលិតផល និងនិយមន័យនៃប្រភេទនីមួយៗមានរាយលំអិតនៅក្នុង តារាង១ និងតារាង២ ។

**តារាង ១: ផលិតផលស្ថិតនៅក្រោមកម្មវិធីប្រមូលផលដើមដៃ**

| ជំពូក ១ | បរិយាយ |
|---|---|
| ០១ | សត្វរស់ |
| ០២ | សាច់និងគ្រឿងក្នុងអាចបរិភោគបាន |
| ០៣ | ត្រី |
| ០៤ | ផលិតផលពីទឹកដោះ |
| ០៥ | ផលិតផលធ្វើពីសត្វផ្សេងទៀត |
| ០៦ | ដើមរុក្ខជាតិរស់ |
| ០៧ | បន្លែ |
| ០៨ | ផ្លែឈើ និងគ្រាប់ឈើអាចបរិភោគបាន |

**តារាង ២: ចំណាត់ថ្នាក់ប្រភេទផលិតផល**

| ប្រភេទ | អាស៊ាន ៦ និង ចិន | សមាជិកអាស៊ានថ្មី |
|---|---|---|
| ១ | ពន្ធគយ MFN > ១៥% | ពន្ធគយ MFN ≥ ៣០% |
| ២ | ៥% < ពន្ធគយ MFN < ១៥% | ១៥% < ពន្ធគយ MFN < ៣០% |
| ៣ | ពន្ធគយ MFN < ៥% | ពន្ធគយ MFN < ១៥% |

** ពន្ធគយ MFN សំដៅលើពន្ធគយអនុវត្តលើប្រទេសដែលទទួលបានការអនុគ្រោះបំផុត*

សមាជិកអាស៊ាន ៦ និងចិន បានផ្តួចផ្តើមអនុវត្តកម្មវិធីកាត់បន្ថយពន្ធគយនៅខែកក្កដា ២០០៣ ដូចមានបង្ហាញក្នុងតារាង ៣ និងកាត់បន្ថយពន្ធគយទាំងអស់ឱ្យដល់សូន្យ នៅខែមករា ២០០៦ ដូចបានគ្រោងទុក ។

សំរាប់សមាជិកអាស៊ានថ្មីដែលមានកម្ពុជាផងដែរ មានការផ្តល់លទ្ធភាពអោយបត់បែនបានច្រើនជាងគេ ដោយត្រូវចាប់ផ្តើមកាត់បន្ថយពន្ធគយនៅពេលក្រោយ និងមានក្របខ័ណ្ឌពេលវេលាវែងជាងសំរាប់អនុវត្ត ដើម្បីកាត់បន្ថយពន្ធគយឱ្យដល់សូន្យនៅឆ្នាំ២០១០ ។

កម្មវិធីប្រមូលផលដើមដៃ ក៏បានអនុញ្ញាតឱ្យប្រទេសជាសមាជិក ដកចេញផលិតផលជាក់លាក់មួយចំនួន ចេញពីក្របខ័ណ្ឌកម្មវិធីដែរ ប៉ុន្តែត្រូវមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងចិន និងសមាជិកអាស៊ានជាប់ពាក់ព័ន្ធ ។ ប្រទេសកម្ពុជាបានដកចេញពីការកាត់បន្ថយពន្ធគយនូវផលិតផល ៣០មុខ ដូចជា ជ្រូករស់ ត្រីរស់ ប៉េងប៉ោះ ខ្ទឹមបារាំង ខ្ទឹមស ផ្កាខាត់ណា ខាត់ណា ស្ពៃក្តោប សាឡាដ ការ៉ុត ស្ពៃមើម ដូង ម្នាស់ ស្វាយ ក្រូច ឪឡឹក ត្រសក់ស្រូវ និង មៀន ។ កម្មវិធីប្រមូលផលដើមដៃ មិនទាន់ទទួលបានសច្ចាប័នពីសភាជាតិនៃ ព្រះរាជាណាចក្រកម្ពុជាទេ ដូច្នេះតាមផ្លូវច្បាប់គឺមិនទាន់ដាក់អនុវត្តបាននៅឡើយទេ ។ទោះយ៉ាងនេះក្តី មានផលិតផល ១៥៥មុខ នៃកម្មវិធីប្រមូលផលដើមដៃ បានទទួលការអនុគ្រោះពន្ធគយមួយចំនួនពីប្រទេសចិន ស្របតាមរបបអនុគ្រោះពិសេសមួយដែលផ្តល់សិទ្ធិឱ្យកម្ពុជានាំចេញទៅចិនដោយជាប់អត្រាពន្ធគយកំរិតទាបនូវទំនិញ ៣៨០មុខ ។

## ៣. ឱកាសល្អខាងសេដ្ឋកិច្ចនៃកម្មវិធីប្រមូលផលដើមដៃ

យោងទៅតាមទ្រឹស្តីសេដ្ឋកិច្ច ការដកចេញរបាំងពន្ធគយ នឹងជួយកាត់បន្ថយថ្លៃដើម ជំរុញសកម្មភាពពាណិជ្ជកម្មក្នុងតំបន់ និងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសធ្វើពាណិជ្ជកម្ម ។ បន្ទាប់ពីបានពិចារណាពីផលិតផលគ្របដណ្តប់ តារាងពេលកាត់បន្ថយពន្ធគយ តំរូវការចិនលើផលិតផលកសិកម្ម និងរចនាសម្ព័ន្ធពាណិជ្ជកម្មរវាងកម្ពុជានិងចិន ឱកាសល្អខាងសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងកម្មវិធីប្រមូលផលដើមដៃ ហាក់ដូចមានទំហំធំធេងណាស់ ជាពិសេសចំពោះ សក្តានុពលនាំចេញផលិតផលកសិកម្ម ។

លំនាំពាណិជ្ជកម្មរវាងចិននិងថៃ ព្រមទាំង ចិននិងវៀតណាម បានបង្ហាញថាទីផ្សារចិនមានតំរូវការច្រើនណាស់នូវផលិតផលក្នុងជំពូកទី៣ (ត្រី បង្គា និង សិប្បិសត្វ) ជំពូកទី៧ (បន្លែ និង ឫសនិងមើមរុក្ខជាតិ) និង ជំពូកទី៨ (ផ្លែឈើ និងគ្រាប់ឈើបរិភោគបាន) ។ ឧទាហរណ៍ នៅឆ្នាំ២០០៥ ប្រទេសចិនបាននាំចូលដំឡូងឈើចំនួន ៣៤១លានដុល្លារ ពីថៃ និង ៥០លានដុល្លារ ពីវៀតណាម ។ ប្រទេសចិន ក៏បាននាំចូលផ្លែឈើ និងគ្រាប់ឈើបរិភោគបានចំនួន ១៨០លានដុល្លារ ហើយ និងត្រី បង្គា និងសិប្បិសត្វចំនួន ៥៧លានដុល្លារ ពីថៃផងដែរ ។

ទំនិញខាងលើមួយចំនួន ស្ថិតក្នុងចំណោមផលិតផលដែលកម្ពុជាកំពុងនាំចេញទៅចិន ហើយមួយចំនួនទៀត មានសក្តានុពលខ្ពស់សំរាប់ធ្វើការអភិវឌ្ឍន៍បំរើការនាំចេញ ។ ត្រីរស់ និងបង្កង គឺជាឧទាហរណ៍ពីរមុខនៃផលិតផលដែលកម្ពុជាកំពុងនាំចេញទៅចិននៅក្រោមកម្មវិធីប្រមូលផលដើមដៃ និងដែលមានតំលៃសរុប ៣,៩៥លានដុល្លារ និង ២,៣៦លានដុលារ ក្នុងកំឡុងឆ្នាំ២០០០-០៥ ។ ផលិតផលទាំងនេះនៅតែសំខាន់ជាខ្លាំង សំរាប់ការនាំចេញ ហើយអាចបង្កើនថែមទៀតបានដើម្បីឆ្លើយតបនឹងតំរូវការរបស់ចិន បន្ទាប់ពីមានការកាត់បន្ថយអត្រាពន្ធគយតាមតារាងពេលនៃកម្មវិធីប្រមូលផលដើមដៃ ។ ចំពោះគុណភាព និងសមត្ថភាពប្រកួតប្រជែង ផលិតផលដំឡូងឈើកម្ពុជាក៏អាចប្រៀបធ្មឹមគ្នាបានជាមួយផលិតផលថៃ និងវៀតណាម ដូច្នេះហើយអាចក្លាយជា ផលិតផលមួយទៀតសំរាប់ការនាំចេញនៅក្រោមកម្មវិធីប្រមូលផលដើមដៃ ។ ចំពោះ ផ្លែឈើស្រស់ ដូចជា ធុរេន មៀន ចេក មង្ឃុត វាជាប្រភេទផ្លែឈើដែលកម្ពុជាអាចផ្គត់ផ្គង់ទៅទីផ្សារចិនបានព្រមគ្នានឹងផលិតផលមកពីថៃ និងវៀតណាមដែរ ។ ផ្លែឈើស្រស់របស់កម្ពុជាមានរសជាតិពិសេសខុសប្លែកពីផ្លែឈើមកពីថៃ និងវៀតណាម ហើយចំណុចនេះអាចជួយសំរួលឱ្យផ្លែឈើកម្ពុជាជ្រៀតចូលទៅក្នុងទីផ្សារចិនបានក្នុងលក្ខណៈជាផលិតផលមានតំរូវការនិងទីផ្សារដោយឡែក (niche market) ។

នៅក្នុងកម្មវិធីប្រមូលផលដើមដៃ គឺមានផលិតផលច្រើនមុខគ្រប់គ្រាន់ហើយសំរាប់ឱ្យប្រទេសមួយ ដូចជា កម្ពុជា អាចថ្លឹងថ្លែងពីឧត្តមភាពប្រៀបធៀប និងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីកំណត់ពីមុខផលិតផលដែលត្រូវផ្តល់អាទិភាព និងធ្វើការឃោសនាផ្សព្វផ្សាយដើម្បីជ្រៀតចូលទៅក្នុងទីផ្សារចិន ។

តារាង ៣ : បែបបទនៃកម្មវិធីប្រមូលផលដើមដៃ លើការកាត់បន្ថយពន្ធគយសំរាប់ប្រទេសចិន

| ប្រភេទផលិតផល | មិនយូរជាងថ្ងៃ ១ មករា ២០០៤ | មិនយូរជាងថ្ងៃ ១ មករា ២០០៥ | មិនយូរជាងថ្ងៃ ១ មករា ២០០៦ |
|---|---|---|---|
| ១ | ១០% | ៥% | 0% |
| ២ | ៥% | 0% | 0% |
| ៣ | 0% | 0% | 0% |

តារាង៤ : បែបបទនៃកម្មវិធីប្រមូលផលដើមដៃ លើការកាត់បន្ថយពន្ធគយសំរាប់កម្ពុជា

| ប្រភេទ ផលិតផល | មិនយូរជាងថ្ងៃ ១ មករា ២០០៤ | មិនយូរជាងថ្ងៃ ១ មករា ២០០៥ | មិនយូរជាងថ្ងៃ ១ មករា ២០០៦ | មិនយូរជាងថ្ងៃ ១ មករា ២០០៧ | មិនយូរជាងថ្ងៃ ១ មករា ២០០៨ | មិនយូរជាងថ្ងៃ ១ មករា ២០០៩ | មិនយូរជាងថ្ងៃ ១ មករា ២០១០ |
|---|---|---|---|---|---|---|---|
| ១ | - | - | ២០% | ១៥% | ១០% | ៥% | 0% |
| ២ | - | - | ១០% | ១០% | ៥% | ៥% | 0% |
| ៣ | - | - | ៥% | ៥% | 0-៥% | 0-៥% | 0% |

## ៤. ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា តាមរយៈកម្មវិធីប្រមូលផលដើមដៃ

តាមរយៈការកាត់បន្ថយពន្ធគយ កម្មវិធីប្រមូលផលដើមដៃបានបង្ហាញពីឱកាសល្អមួយដែលបើកចំហ ប៉ុន្តែចំណុចនេះមិនមែនជាកត្តាតែមួយដែលកំណត់ពីជោគជ័យនៃការនាំចេញនោះទេ ព្រោះនៅមានសកម្មភាព និងវិធានការជាច្រើនទៀតដែលត្រូវអនុវត្តដោយអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួន ដូចជា រដ្ឋាភិបាល និងវិស័យឯកជនជាដើម ។

វិធានការទាំងនេះមានជាសង្ខេបដូចតទៅ:

- វិស័យឯកជនគួររួមសហប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជា ធ្វើការសិក្សាស៊ីជំរៅមួយទាក់ទងនឹងបែបបទនៃតំរូវការនៅទីផ្សារចិន ដូចជា ចំណង់ចំណូលចិត្តរបស់អតិថិជនចំពោះផ្លែឈើស្រស់ជាដើម ។ ការសិក្សានេះមិនបាច់ធ្វើអោយគ្រប់ទីផ្សាររបស់ចិនទេ ប៉ុន្តែអាចផ្តោតលើតែទីផ្សារធំបងៗ ដូចជាទីផ្សារលក់ដុំផ្លែឈើនៅខេត្ត Guangzhou ជាដើម ។ លទ្ធផលនៃការសិក្សានេះ នឹងធ្វើឱ្យសហគ្រិនអាចយល់ដឹងបានប្រសើរថែមទៀតពីទីផ្សាររបស់ចិន ហើយកសាងបាននូវតំរូវការនិងទីផ្សារដោយឡែក សំរាប់ផលិតផលកសិកម្មកម្ពុជា ។
- កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងសមាគមពាណិជ្ជកម្មនៃប្រទេសទាំងពីរ ត្រូវតែពង្រឹងបន្ថែម ។ សហគ្រាសនានានៅកម្ពុជា អាចប្រើប្រាស់ពួកដៃគូពាណិជ្ជកម្មចិនរបស់ខ្លួន ធ្វើជាច្រកសំរាប់ចែករំលែក ផ្តល់ព័ត៌មានឱ្យគ្នា ។
- ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ដូចជា ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាដើម គួរតែកសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយមួយ សំរាប់ផលិតផលនាំចេញសក្តានុពលដូចបានរៀបរាប់ខាងលើដោយសង្កត់ធ្ងន់ទៅលើការស្វែងរកដំណោះស្រាយចំពោះកំហិតសំខាន់ៗដែលរារាំងការអភិវឌ្ឍន៍វិស័យកសិកម្ម ។ កំហិតទាំងនេះ មានដូចជាហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ (ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព) សេវាកម្មបច្ចេកទេសមិនគ្រប់គ្រាន់ កង្វះប្រព័ន្ធម៉ាឃីតទីងដ៏មានប្រសិទ្ធភាព ការកាន់កាប់ដីគ្មានសុវត្ថិភាព និងកង្វះលទ្ធភាពទទួលបានធាតុចូលកសិកម្ម ។
- ត្រូវមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ពីរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីចាប់អនុវត្តគំនិតផ្តួចផ្តើមកសាងតំបន់អភិវឌ្ឍន៍កសិកម្មពិសេស (Special Agricultural Development Zone: SADZ) ដែលអាចផ្តល់ភាពងាយស្រួលច្រើន ដល់ការអភិវឌ្ឍន៍ផលិតផលជាក់លាក់មួយចំនួនដោយផ្អែកលើលក្ខណៈខាងភូមិសាស្ត្រ ។ យុទ្ធសាស្ត្រកសាងតំបន់អភិវឌ្ឍន៍កសិកម្មពិសេស មានចំណុចខ្លាំងជាច្រើន បើធៀបនឹងវិធីសាស្ត្របច្ចុប្បន្ននៃការអភិវឌ្ឍន៍កសិកម្ម ។ ទី១ វាជួយឱ្យរដ្ឋាភិបាលអាចផ្តោតការប្រឹងប្រែងទៅលើតំបន់ជាក់លាក់ណាមួយ ដូច្នេះគឺអាចបែងចែកធនធានដ៏កំរ និងកំលាំងគ្រប់គ្រងទៅលើតំបន់តូចជាងមុន ដើម្បីទទួលបានផលច្រើនជាអតិបរមា ជាជាងពង្រាយការប្រឹងប្រែងទៅលើតំបន់ធំទូលាយ ហើយមិនសូវផ្តោតខ្លាំង ។ ទី២: វាមានភាពងាយស្រួលជាងដើម្បីធ្វើការសាកល្បង ពិនិត្យតាមដាន រឺផ្លាស់ប្តូរកែលំអ ក៏ដូចជាផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដ៏ចាំបាច់ ដូចជា ម៉ាឃីតទីង កន្លែងស្តុកការដឹកជញ្ជូន និងប្រព័ន្ធកែច្នៃជាដើម ។ ទី៣: ដំណើរការអភិវឌ្ឍន៍នឹងកាន់តែជាក់ស្តែងថែមទៀត បើសិនអាចទាក់ទាញអ្នកឯទៀតឱ្យមកចូលរួមរៀនសូត្រតាមការអនុវត្តន៍ជាក់ស្តែង នៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ ។
- បទប្បញ្ញត្តិស្តីពីការសំរបសំរួលពាណិជ្ជកម្មសំរាប់វិស័យឯកជន គួរតែកែលំអបន្ថែមទៀតក្នុងចំណុចដូចជា ព័ត៌មានទាក់ទងនឹងពាណិជ្ជកម្ម ការផ្តល់ព័ត៌មានទាន់ពេលស្តីពីការចរចាពាណិជ្ជកម្ម ការវិវត្តន៍នៃគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនិងជាពិសេសការសំរបសំរួលពាណិជ្ជកម្ម ។ រដ្ឋាភិបាល ក៏គួរដើរតួនាទីយ៉ាងសកម្មថែមទៀតក្នុងការទប់ស្កាត់ការយកប្រាក់កំរៃក្រៅផ្លូវការ និងក្នុងការធ្វើឱ្យនីតិវិធីនៃការនាំចូលនាំចេញមានភាពសាមញ្ញងាយស្រួល ។

## ៥. សេចក្តីសង្ខេប និងសន្និដ្ឋាន

កម្មវិធីប្រមូលផលដើមដៃរវាងអាស៊ាននិងចិន កើតមានឡើងចំពេលដែលរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអភិវឌ្ឍវិស័យកសិកម្មឱ្យទៅជា ប្រភពមួយថែមទៀតនៃកំណើនសេដ្ឋកិច្ច ។ កម្មវិធីនេះគេប្រមើលឃើញថា មានលទ្ធភាពច្រើនដើម្បីជួយជំរុញការអភិវឌ្ឍន៍កសិកម្ម តាមរយៈឱកាសល្អសំរាប់នាំចេញផលិតផលដូចជា ដំឡូងឈើ ផ្លែឈើស្រស់ ត្រី និងបង្កង ជាដើម ប៉ុន្តែត្រូវមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងភាពជាដៃគូស៊ីជំរៅជាងមុនរវាងប្រទេសទាំងពីរ ទាំងនៅកំរិតរដ្ឋាភិបាល និងកំរិតសហគ្រាសអាជីវកម្ម ។ ទោះធ្វើបានដូច្នេះក៏នៅតែមិនទាន់គ្រប់គ្រាន់សំរាប់ឱ្យប្រទេសកម្ពុជា ទទួលបានអត្ថប្រយោជន៍ធំៗពីកម្មវិធីប្រមូលផលដើមដៃ លើកលែងតែអ្នកពាក់ព័ន្ធសំខាន់ៗក្នុងពាណិជ្ជកម្មផលិតផលកសិកម្ម ដូចជា រដ្ឋាភិបាល វិស័យឯកជន និងសហគមអ្នកផ្តល់ជំនួយជាដើម បានចាត់វិធានការរៀងៗខ្លួន និងរួមគ្នា ដើម្បីលើកស្ទួយសមត្ថភាពប្រកួតប្រជែងនៃវិស័យកសិកម្ម ។

- កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ រវាងរដ្ឋនិងរដ្ឋ: កម្ពុជាគួរស្វែងរកជំនួយអភិវឌ្ឍន៍ និងជំនួយបច្ចេកទេសពីប្រទេសចិន សំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ។
- កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងសហគ្រាសនិងសហគ្រាស: សមាគមពាណិជ្ជកម្មកម្ពុជា គួរពង្រឹងទំនាក់ទំនងជាដៃគូជាមួយសមាគមនៅប្រទេសចិន ដើម្បីទទួលបានព័ត៌មានទីផ្សារ និងជំរុញការចែកចាយផលិតផលកសិកម្មកម្ពុជា ។
- ភាពជាដៃគូរវាងសហគ្រាសនិងរដ្ឋ: រដ្ឋាភិបាលកម្ពុជាដាក់អនុវត្តយុទ្ធសាស្រ្តមួយសំរាប់ការអភិវឌ្ឍន៍ផលិតផលជាក់លាក់មួយចំនួន ក្នុងនេះមានទាំងការដោះស្រាយបញ្ហាវិកំហិតផ្សេងៗ ដែលវិស័យឯកជនបានលើកឡើង ។
- ជំនួយគាំទ្រពីសហគមន៍អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល: ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ត្រូវមានជាចាំបាច់ដើម្បីជួយទ្រទ្រង់ដល់ការអភិវឌ្ឍន៍វិស័យកសិកម្មជាទូទៅ និងជាពិសេស ការអភិវឌ្ឍន៍ផលិតផលសក្តានុពល ។

ដោយគួបផ្សំជាមួយវិធានការទាំងឡាយដូចខាងលើ កម្មវិធីប្រមូលផលដើមដៃអាចក្លាយជាឧបករណ៍ដ៏ខ្លាំងក្លាសំរាប់ជំរុញ ការនាំចេញផលិតផលកសិកម្ម និងការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ។

## កំណត់សំគាល់

១. កិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវបានចុះហត្ថលេខានៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៨ នៅឆ្នាំ២០០២ នៅក្រុងភ្នំពេញ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងវិនិយោគថែមទៀត ព្រមទាំងបង្កើតតំបន់ពាណិជ្ជកម្មសេរីក្នុងកំឡុងពេល ១០ឆ្នាំ ។

២. Toshiyasu, Chan and Long (1998) អ្នកនិពន្ធទាំងនេះបានស្រាវជ្រាវពីកត្តានានា ដែលកំណត់ឧត្តមភាពប្រៀបធៀបរបស់ប្រទេសអាស៊ានមួយចំនួនដោយផ្អែកលើភស្តុតាងពិនិត្យឃើញជាក់ស្តែង ។

## ឯកសារយោង


______ (2002), *Framework Agreement on Comprehensive Economic Cooperation Between The Association of South East Asian Nations and the People's Republic of China* (Jakarta: ASEAN Secretariat)

______ (2006), *CDRI's Roundtable Discussion on the Early Harvest Programme and its Implications for Cambodian Agriculture* (Phnom Penh: CDRI)

Cordenillo, Raul L. (2005), *The Economic Benefits for ASEAN of the ASEAN-China Free Trade Area (ACFTA)* (Jakarta: ASEAN Secretariat)

Chayodom Sabhasri *et. al.* (2005), *ASEAN and China Free Trade Area: Implications for Thailand* (Bangkok: Ministry of Commerce)

Vutha HING and Nou Koesothea (2006), The *Early Harvest Programme: Implications for Cambodia Agriculture* (Phnom Penh: CDRI)

Toshiyasu K., Chan S. and Long P. (1998), *Regional Economic Integration for Sustainable Development in Cambodia*, Working Paper 5 (Phnom Penh: CDRI).


## សង្ខេបសំរាប់គោលនយោបាយថ្មីៗពី វបសអ

១. និន្នាការនៃការបាត់បង់ និងខូចខាតព្រៃឈើ ខែមីនា ២០០៦ លេខ ១ ដោយ ហ៊ៅ-គឹមស្រេង ឃ្លោក-បុត្រា កាស្ទើ-ហាសិន និង គ្រីស្ទាន-ស្លូត

២. តំលៃធនធានព្រៃឈើចំពោះជីវភាពនៅជនបទកម្ពុជា ខែមីនា ២០០៦ លេខ ២ ដោយ ហ៊ៅ-គឹមស្រេង ឃ្លោក-បុត្រា កាស្ទើ-ហាសិន និង គ្រីស្ទាន-ស្លូត

៣. ផលិតភាពឈើហ៊ុបនៃប្រភេទព្រៃឈើមួយចំនួន ខែមីនា ២០០៦ លេខ ៣ ដោយ ហ៊ៅ-គឹមស្រេង ឃ្លោក-បុត្រា កាស្ទើ-ហាសិន និង គ្រីស្ទាន-ស្លូត

៤. ជំរើសក្នុងការគ្រប់គ្រងព្រៃឈើនៅកម្ពុជាខែមីនា ២០០៦ លេខ ៤ ដោយ ហ៊ៅ-គឹមស្រេង ឃ្លោក-បុត្រា កាស្ទើ-ហាសិន និង គ្រីស្ទាន-ស្លូត


©២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា



☞ ផ្ទះលេខ 56 ផ្លូវលេខ 315 ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា ( ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា)

☎ (855-23) 881-384/881-701/ 883-603/ 881-916 🖷 (855-23) 880-734

អ៊ីមែល: cdri@camnet.com.kh http://www.cdri.org.kh